**សកម្មភាព** ៖ **ល្បែងស្ដាប់ពណ៌**

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**ភាសាខ្មែរ**

ការស្ដាប់ (ស្ដាប់គេនិយាយ និងមានសម្ថភាពស្ដាប់ដោយធ្វើតាមការណែនាំងាយៗ)។

**គោលបំណង** ៖

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**(ភាសាខ្មែរ)** ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើនរណាជាអ្នកលាបពណ៌មេឃ?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ សន្លឹកកិច្ចការ (B3-PW-3_ល្បែងគូរដានឥន្ទធនូ) និងខ្មៅដៃពណ៌។

**ការរៀបចំ** ៖ ធ្វើបញ្ជីនៃធាតុដែលជាពណ៌ខុសគ្នានៃឥន្ទធនូ ដូច្នេះអ្នកអាចជួយក្មេងៗប្រសិនបើចាំបាច់។ បោះពុម្ពសន្លឹកកិច្ចការចេញ (សន្លឹកមួយសម្រាប់ក្មេងម្នាក់)។

**សេចក្តីណែនាំ៖**

1. តើកូនៗអាចប្រាប់ពណ៌របស់ឥន្ទធនូទាំងប្រាំពីរបានទេ? ក្មេងម្នាក់បានឆ្លើយពណ៌ ឱ្យក្មេងម្នាក់ទៀតឆ្លើយ វត្ថុដែលមានពណ៌ដូចនឹងពណ៌។
   ឧទាហរណ៍៖ ក្មេងម្នាក់ឆ្លើយ ឥន្ទធនូមានពណ៌ក្រហម ចំណែកឯក្មេងម្នាក់ទៀតឆ្លើយថា កម្រាលតុមានពណ៌ក្រហមដូច ពណ៌ឥន្ទធនូដែរ។
2. បន្តធ្វើសកម្មភាពបែបនេះរហូតដល់គ្រប់៧ពណ៌។
3. សេចក្តីណែនាំដូចខាងក្រោមសម្រាប់ការលេងល្បែងនេះ៖
   - ចាប់ផ្តើមជាមួយនឹងពណ៌ក្រហម និងនិយាយថា‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមាន
     ដាក់វត្ថុដែលមាន
     ពណ៌ក្រហម) ...» ឧទាហរណ៍. ផ្លែប៉េងប៉ោះ។
   - ក្មេងទី២ និយាយបន្តទៀតថា ‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមានប៉េងប៉ោះ និងផ្លែប៉ោម (ដាក់វត្ថុដែលមានពណ៌ក្រហមមួយមុខទៀត) ឧទាហរណ៍. មាន ប៉េងប៉ោះ ប៉ោម។

- ក្មេងទី៣ និយាយឈ្មោះផ្លែទាំង២មាន ប៉េងប៉ោះ ប៉ោម និងដាក់វត្ថុ ឬផ្លែមួយទៀត ដែលមានពណ៌ក្រហមដូចគ្នា។ ឧទាហរណ៍. ‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមាន ផ្លែប៉េងប៉ោះ ផ្លែប៉ោម និងផ្លែស្រកានាគ… ››។
- ធ្វើបែបនេះរហូត បើក្មេងណាម្នាក់ភ្លេចពណ៌វត្ថុ ឬឈ្មោះវត្ថុដែលពួកគេបាននិយាយទាំងនោះ ពួកគេនឹងត្រូវចាកចេញពីការលេងល្បែងនេះ។
- លេងរហូតគ្រប់ពណ៌ឥន្ទធនូទាំងប្រាំពីរមានដូចជា ស្វាយ ខៀវស្វាយ និងពណ៌ផ្សេងទៀត។

4. ប្រសិនបើមានបញ្ហា ឬ មិនយល់ អ្នកអាចនិយាយឧទាហរណ៍ខ្លះៗ។
5. ចែកខ្មៅដៃពណ៌ និងឱ្យពួកគេផាត់ពណ៌ដែលមាននៅខាងក្រោមរូបនីមួយៗ ជាការស្រេច។

**ការប្រែប្រួលៈ**

ល្បែងនេះអាចលេងជាក្រុមក៏បានដែរ។